**ព្រឹទ្ធសភា**

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
## ស្តីពី
## លទ្ធផលការងាររបស់ព្រឹទ្ធសភាប្រចាំខែវិច្ឆិកា ឆ្នាំ២០២០

នៅក្នុងខែវិច្ឆិកា ឆ្នាំ២០២០នេះ ព្រឹទ្ធសភាបានបំពេញភារកិច្ចដូចតទៅៈ

**១-សកម្មភាពថ្នាក់ដឹកនាំព្រឹទ្ធសភា**

**១.១ សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា**

-បានបំពេញភារកិច្ចជាប្រមុខរដ្ឋស្តីទីចាប់ពីថ្ងៃទី៦ ខែតុលា ឆ្នាំ២០២០។

**ក-សកម្មភាពចូលរួមកិច្ចប្រជុំ**

-បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន១លើក និងសម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី៦ នីតិកាលទី៤ ចំនួន១លើក។

**ខ-បដិសណ្ឋារកិច្ចជាមួយភ្ញៀវជាតិ និងអន្តរជាតិ**

-បានអនុញ្ញាតឱ្យឯកឧត្តម Michael Tan ឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋសិង្ហបុរី ចូលជួបសម្តែងការគួរសម និងជម្រាបលា

-បានអនុញ្ញាតឱ្យនិស្សិតជ័យលាភីអាហារូបករណ៍រដ្ឋាភិបាលអូស្ត្រាលី និងញូវែល-ហ្សេឡង់ចំនួន២៧រូប ចូលជួបសម្តែងការគួរសម មុនពេលចេញទៅសិក្សានាខែមករា ឆ្នាំ២០២១។

**គ-សកម្មភាពចុះមូលដ្ឋាន**

-បានអញ្ជើញចុះសួរសុខទុក្ខមន្ត្រី អាជ្ញាធរ សង្កាត់ និងកងកម្លាំងនគរបាលប៉ុស្តិ៍ កម្លាំងប្រជាការពារ និងប្រជាពលរដ្ឋរងគ្រោះដោយជំនន់ទឹកភ្លៀង នៅសង្កាត់សាក់សំពៅ ខណ្ឌដង្កោ រាជធានីភ្នំពេញ។

**ឃ-សកម្មភាពចូលរួមពិធីផ្សេងៗ**

-បានអញ្ជើញចូលរួមទទួលព្រះរាជដំណើររបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ស្តេចយាងនិវត្តន៍

ពីសាធារណរដ្ឋប្រជាមានិតចិនមកកាន់មាតុប្រទេសវិញ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ

-បានអញ្ជើញចូលរួមជាគណៈអធិបតីក្នុងពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី៦៧ នៃទិវាបុណ្យឯករាជ្យជាតិ៩ វិច្ឆិកា និងដង្ហែ**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីប្រទានភ្លើងជ័យ និងពន្លត់ភ្លើងជ័យ នៅវិមានឯករាជ្យ

-បានអញ្ជើញចូលរួមរំលែកទុក្ខជាមួយក្រុមគ្រួសារសពឧបាសិកា **អ៊ួង មិ** នៅវត្តព្រះធាតុ សង្កាត់រលួស ខណ្ឌដង្កោ រាជធានីភ្នំពេញ។

**ង-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-បានចុះហត្ថលេខាលើព្រះរាជក្រឹត្យចំនួន៣៨ច្បាប់

-បានទទួលព្រះរាជសារព្រះរាជទានសិទ្ធិចំនួន១៩ច្បាប់

-បានទទួលសំណើពីរាជរដ្ឋាភិបាលចំនួន១៨ច្បាប់

-បានទទួលសំណើពីរដ្ឋសភាចំនួន១ច្បាប់

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន៣៥ច្បាប់ និងជ្រាបជាព័ត៌មានចំនួន១៥ច្បាប់។

**១.២ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ស៊ុំ កា អនុប្រធានទី១ព្រឹទ្ធសភា**

-បានទទួលភារកិច្ចជាប្រធានស្តីទីព្រឹទ្ធសភាចំនួន១លើក។

**ក-សកម្មភាពចូលរួមកិច្ចប្រជុំ**

-បានអញ្ជើញដឹកនាំកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន២លើក និងសម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី៦ នីតិកាលទី៤ ចំនួន១លើក។

**ខ-សកម្មភាពចូលរួមពិធីផ្សេងៗ**

-បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីប្រទានភ្លើងជ័យ និងពន្លត់ភ្លើងជ័យ នៃទិវាបុណ្យឯករាជ្យជាតិ៩ វិច្ឆិកា និងទិវាខួបកំណើតនៃកងយោធពលខេមរភូមិន្ទ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅវិមានឯករាជ្យ។

**គ-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន២៨ច្បាប់ និង

ជ្រាបជាព័ត៌មានចំនួន៥០ច្បាប់។

**១.៣ ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា**

**ក.សកម្មភាពចូលរួមប្រជុំ**

-បានអញ្ជើញចូលរួមប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន២លើក និងសម័យប្រជុំពេញអង្គព្រឹទ្ធសភា លើកទី៦ នីតិកាលទី៤ ចំនួន១លើក ក្រោមអធិបតីភាពឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **ស៊ុម កា** ប្រធានស្តីទីព្រឹទ្ធសភា។

**ខ-សកម្មភាពចូលរួមពិធីផ្សេងៗ**

-បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភាថ្វាយកម្រងផ្កា និងគោរពវិញ្ញាណក្ខន្ធ **ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុ ព្រះបរមរតនកោដ្ឋ** ក្នុងឱកាសប្រារព្ធពិធីខួបអនុស្សាវរីយ៍លើកទី៦៧ នៃទិវាបុណ្យឯករាជ្យជាតិ នៅមណ្ឌបតម្កល់ព្រះបរមរូប រាជធានីភ្នំពេញ

-បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីបុណ្យខួបអនុស្សាវរីយ៍លើកទី៦៧ នៃទិវាបុណ្យឯករាជ្យជាតិ៩ វិច្ឆិកា និងដង្ហែ**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងពិធីប្រទានភ្លើងជ័យ និងពន្លត់ភ្លើងជ័យ នៅវិមានឯករាជ្យ

-បានអញ្ជើញចូលរួមពិធីបុណ្យទក្ខិណានុប្បទាន និងរាប់បាត្រព្រះសង្ឃឧទ្ទិសកុសលផលបុណ្យជូនដល់ដួងវិញ្ញាណក្ខន្ធ**សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម** អតីតប្រធានព្រឹទ្ធសភា និង**លោកជំទាវ** ព្រមទាំងញាតិការទាំងប្រាំពីរសណ្តាន នៅភូមិកន្លែងជ្រៅ ឃុំក្រពៅ ស្រុកកំចាយមារ ខេត្តព្រៃវែង។

**គ-ការពិនិត្យ និងផ្តល់យោបល់លើឯកសារផ្សេងៗ**

-ពិនិត្យ ផ្តល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១៤ច្បាប់ និងជ្រាបជាព័ត៌មានចំនួន២៥ច្បាប់។

## ២.សម័យប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន២លើក

គណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាបានបើកកិច្ចប្រជុំចំនួន២លើក ដើម្បីពិនិត្យសំណើរបស់រដ្ឋសភាសុំពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន៦ច្បាប់ ដូចខាងក្រោម៖

១-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារខណ្ឌសីមា និងបោះ

បង្គោលព្រំដែនគោករវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម

២-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពី ការហាមឃាត់អាវុធនុយក្លេអ៊ែរ

៣-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទី១ ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងស្តីពី ភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយរវាងរដ្ឋជាសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងជប៉ុន

៤-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារអនុវត្តកញ្ចប់សន្យាទី១០ ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម

៥-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី ការវិនិ-យោគក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពី កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋឥណ្ឌា

៦-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី ការវិនិ-យោគរវាងបណ្តារដ្ឋសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងរដ្ឋាភិបាល នៃតំបន់រដ្ឋបាលពិសេសហុងកុង នៃសាធារណរដ្ឋប្រជាមានិតចិន។

## ៣.សម័យប្រជុំពេញអង្គព្រឹទ្ធសភា ចំនួន១លើក

ព្រឹទ្ធសភាបានបើកសម័យប្រជុំលើកទី៦ នីតិកាលទី៤ ដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងច្បាប់ចំនួន៦ច្បាប់ដូចខាងក្រោម៖

១-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារខណ្ឌសីមា និងបោះបង្គោលព្រំដែនគោករវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណរដ្ឋសង្គមនិយមវៀតណាម

២-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើសន្ធិសញ្ញាស្តីពី ការហាមឃាត់អាវុធនុយក្លេអ៊ែរ

៣-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទី១ ធ្វើវិសោធនកម្មកិច្ចព្រមព្រៀងស្តីពី ភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយរវាងរដ្ឋជាសមាជិកសមាគមប្រជា-ជាតិអាស៊ីអាគ្នេយ៍ និងជប៉ុន

៤-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារអនុវត្តកញ្ចប់សន្យាទី១០ ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពី សេវាកម្ម

៥-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពីការវិនិយោគក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពី កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចទូលំទូលាយរវាងសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងសាធារណរដ្ឋឥណ្ឌា

៦-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្តីពី ការវិនិយោគរវាងបណ្តារដ្ឋសមាជិកនៃសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ និងរដ្ឋាភិបាលនៃតំបន់រដ្ឋបាលពិសេសហុងកុង នៃសាធារណរដ្ឋប្រជាមានិតចិន។

## ៤.គណៈកម្មការជំនាញនានារបស់ព្រឹទ្ធសភា

សមាជិក សមាជិកាព្រឹទ្ធសភា បានបំពេញការងារយ៉ាងសកម្មតាមតួនាទី ភារកិច្ច និងសមត្ថកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដូចខាងក្រោមៈ

### ៤.១ មុខងារនីតិកម្ម

គណៈកម្មការជំនាញព្រឹទ្ធសភា បានប្រជុំអន្តរគណៈកម្មការជាមួយតំណាងរាជរដ្ឋាភិបាល ដើម្បីពិនិត្យសិក្សាលើសេចក្តីព្រាងច្បាប់ចំនួន៦ច្បាប់។

### ៤.២ មុខងារតំណាង

-បានទទួលពាក្យបណ្តឹងចំនួន៣ករណី ធ្វើលិខិតអន្តរាគមន៍ទៅក្រសួង-ស្ថាប័នពាក់ព័ន្ធដើម្បីដោះស្រាយចំនួន២ករណី ធ្វើកំណត់បង្ហាញពាក្យបណ្តឹងចំនួន២ករណី និងទទួលលិខិតឆ្លើយតបពីការដោះស្រាយពាក្យបណ្តឹងពីស្ថាប័នពាក់ព័ន្ធចំនួន៤ករណី ឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន៣ករណី តម្កល់ទុកមិនចាត់ការចំនួន១ករណី និងទទួលឯកសារពាក្យបណ្តឹងដែលក្រសួង-ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការ ដើម្បីជូនជ្រាបចំនួន១ករណី

-បានអញ្ជើញចូលរួមវេទិកាផ្សព្វផ្សាយស្តីពី ការរំលោភបំពាន និងបៀតបៀនផ្លូវភេទនៅសាលាសង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ

-បានអញ្ជើញចូលរួមប្រជុំពិភាក្សាការងាររៀបចំគ្រឿងឥស្សរិយយសសម្រាប់បំពាក់ជូនសមាជិកព្រឹទ្ធសភានៅពាក់កណ្តាលនីតិកាលទី៤

-បានអញ្ជើញចូលរួមកិច្ចប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើគម្រោងបែងចែកកញ្ចប់ថវិកាប្រចាំឆ្នាំ២០២១របស់ព្រឹទ្ធសភា

-បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំស្តីពី ការរៀបចំឯកសារសំខាន់ៗ ដើម្បីត្រៀមរៀបចំធ្វើវេទិការបស់ក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី១

-បានអញ្ជើញចូលរួមអបអរសាទរទិវាជាតិអាហាររូបត្ថម្ភលើកទី៧ ក្រោមប្រធានបទ ការពង្រឹងប្រព័ន្ធស្បៀងដើម្បីរបបអាហារសុខភាព ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម **យឹម ឆៃលី** ឧបនាយករដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការជាតិដើម្បីស្តារ អភិវឌ្ឍន៍កសិកម្មជនបទ

សមាជិក សមាជិកាព្រឹទ្ធសភា បានអញ្ជើញចុះជួបពិភាក្សាការងារជាមួយសមាជិក ក្រុមប្រឹក្សាឃុំ សង្កាត់ សំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋរងគ្រោះដោយ ជំនន់ទឹកភ្លៀង ចែកអំណោយ និងអប់រំផ្សព្វផ្សាយវិធីបង្ការនិងទប់ស្កាត់ជំងឺកូវីដ-១៩ ដល់ប្រជាពលរដ្ឋ ពិនិត្យការដ្ឋានសាងសង់ សម្ពោធសមិទ្ធផលនានា តាមដានការអនុវត្ត គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិ ការអនុវត្តគោល នយោបាយភូមិ ឃុំ មានសុវត្ថិភាព ការអនុវត្តច្បាប់ កែលម្អសេវាសាធារណៈ ពង្រឹង អភិបាលកិច្ចល្អនៅមូលដ្ឋាន និងគោលនយោបាយផ្សេងៗលើគ្រប់វិស័យ ព្រមទាំង ចូលរួមពិធីផ្សេងៗនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានាចំនួន១២០លើក។

## ៤.៣ កិច្ចសហប្រតិបត្តិការអន្តរជាតិ

-សមាជិកព្រឹទ្ធសភា បានអញ្ជើញចូលរួមប្រជុំក្រុមភូមិសាស្ត្រនយោបាយតំបន់ អាស៊ី-ប៉ាស៊ីហ្វិក (APG) ដែលរៀបចំដោយសភានៃប្រទេសហ្វីលីពីន តាមប្រព័ន្ធវីដេអូ

-សមាជិកព្រឹទ្ធសភា បានអញ្ជើញចូលរួមមហាសន្និបាតប្រចាំឆ្នាំនៃបណ្តាញក្រុម សីលធម៌សមាជិកសភាប្រើភាសាបារាំង តាមប្រព័ន្ធវីដេអូ ដែលផ្សាយចេញពីខេត្ត Quebec ប្រទេសកាណាដា ក្រោមអធិបតីភាពលោកស្រី **Mignolet Ariane** ប្រធានបណ្តាញក្រុម សីលធម៌សមាជិកសភាប្រើភាសាបារាំង

-សមាជិកព្រឹទ្ធសភា បានអញ្ជើញចូលរួមមហាសន្និបាតវិសាមញ្ញលើកទី២០៦ នៃ ក្រុមប្រឹក្សាភិបាលសហភាពអន្តរសភា (IPU) តាមប្រព័ន្ធវីដេអូ ផ្សាយចេញពីទីក្រុងហ្សឺណែវ ប្រទេសស្វីស ដើម្បីអនុម័តវិធាននីតិវិធីពិសេសនៃកិច្ចប្រជុំតាមប្រព័ន្ធវីដេអូ, អនុម័តរបាយ-ការណ៍សង្ខេបនៃកិច្ចប្រជុំក្រុមប្រឹក្សាភិបាលលើកទី២០៥ នៅទីក្រុងបែលក្រាត, អនុម័ត សេចក្តីព្រាងថវិកាសម្រាប់ឆ្នាំ២០២១, អនុម័តរបាយការណ៍លទ្ធផលហិរញ្ញវត្ថុរបស់ (IPU) សម្រាប់ឆ្នាំ២០១៩, របាយការណ៍សង្ខេបស្តីពីលទ្ធផលនៃសន្និសីទប្រធានសភាពិភពលោក

លើកទី៥ និងកិច្ចប្រជុំកំពូលនៃប្រធានសភាជាស្ត្រីលើកទី១៣, ការបោះឆ្នោតជ្រើសរើស សមាជិកគណៈកម្មាធិការប្រតិបត្តិ និងការបោះឆ្នោតជ្រើសរើសប្រធាន(IPU)ថ្មីសម្រាប់ អាណត្តិ ២០២០-២០២៣។

ថ្ងៃ ចន្ទ 14 រោច ខែមិគសិរ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

រាជធានីភ្នំពេញ, ថ្ងៃទី 14 ខែធ្នូ ឆ្នាំ២០២០

**ជ.ប្រធានព្រឹទ្ធសភា**

**អនុប្រធានទី២**

កិត្តិសង្គហបណ្ឌិត **ទេព ងន**

*ចម្លងជូន*

- *ក្រសួងព្រះបរមរាជវាំង*
- *ក្រុមប្រឹក្សាធម្មនុញ្ញ*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ*
- *ក្រសួងយុត្តិធម៌*
- *ក្រសួងព័ត៌មាន*
- *(ទូលថ្វាយ និងជូនជ្រាបជាព័ត៌មាន)*
- *កាលប្បវត្តិ-ឯកសារ*